ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សៀវភៅបច្ចេកទេស

# ការកែលម្អវិធីសាស្ត្រចិញ្ចឹមមាន់ លក្ខណៈគ្រួសារ



សម្រាប់កសិករ

២០១១

# សារៈសំខាន់នៃការអានសៀវភៅនេះ



១.ឱ្យកសិករ ចេះបច្ចេកទេសចិញ្ចឹបមាន់ក្នុងរបងជាលក្ខណៈគ្រួសារ ដោយផ្តល់នូវចំណីដែលមានគុណភាព ដើម្បីទទួលបានផលចំណេញ និងមានសុវត្ថិភាព។

២.ឱ្យកសិករយល់ដឹងអំពីអត្ថប្រយោជន៍នៃការចិញ្ចឹបមាន់ជាលក្ខណៈគ្រួសារ។



AIDOC
Code: 230-009
Date:
Donated by:

## ផ្លាស់ប្តូរពី:

**-ការចិញ្ចឹមតាមទំលាប់ (ព្រលែង):** គ្មានជម្រក គ្មានការផ្តល់ចំណី គ្មានការថែទាំសុខភាព និងគ្មានការចាក់ថ្នាំការពារឱ្យបានត្រឹមត្រូវ





## មកជា:

**-ការចិញ្ចឹមមាន់ក្នុងរបងជុំវិញទ្រុងនៅក្បែរផ្ទះ:** កសិករបានលទ្ធភាពផ្តល់ចំណី និងថែទាំសុខភាពរបស់មាន់បានល្អ និងចាក់ថ្នាំការពារសុខភាពឱ្យមាន់បានល្អ។

# អត្ថប្រយោជន៍នៃការចិញ្ចឹមមាន់ក្នុងរបងជាលក្ខណៈគ្រួសារ

មាន់ត្រូវបានចិញ្ចឹមនៅក្នុងរបងក្បែរផ្ទះ

↓

- ការពារមាន់បានល្អ
- ងាយស្រួលក្នុងការតាមដានសុខភាពរបស់មាន់
- ងាយស្រួលក្នុងការផ្ដល់ចំណី-ទឹក

មាន់ត្រូវបានផ្ដល់ឱ្យនូវចំណីធម្មជាតិ

↓

- ចំណាយទុនតិច ពីព្រោះអាចប្រើធនធានចំណីនៅជុំវិញផ្ទះ និងក្នុងភូមិ
- ចំណីមានគុណភាពល្អគ្មានជាតិគីមី

↓

មាន់មានសុខភាពល្អ និងមិនងាយឈឺស្លាប់



ស៊ុត និងសាច់សំរាប់បរិភោគ



ទទួលបានកូនមាន់សុខភាពល្អទុកធ្វើពូជ (មាន់មេមួយក្បាលផ្តល់កូនប្រមាណ ៦០ក្បាល/ឆ្នាំ)



បង្កើនប្រាក់ចំណូលពីការលក់មាន់

# ស្ត្រីដើរតួនាទីយ៉ាងសំខាន់នៅក្នុងការងារចិញ្ចឹមមាន់

-ជាលក្ខណៈប្រពៃណីសង្គមខ្មែរ ស្ត្រីបានតួនាទីធ្វើការងារនៅជុំវិញផ្ទះ ពួកគាត់អាចចិញ្ចឹមសត្វផង និងធ្វើកិច្ចការផ្ទះបានទៀតផងក៏ដូចជាការដាំដុះផ្សេងៗ

-វាងាយស្រួលគ្រប់គ្រង និងត្រូវការទុនតិច

-ផ្តល់ចំណូលដល់ស្ត្រីសម្រាប់ផ្គត់ផ្គង់គ្រួសារ ដែលជួយលើកកំពស់បុខមាត់ពួកគាត់ក្នុងគ្រួសារនិងក្នុងសង្គម និងធ្វើឱ្យស្ត្រីបានសិទ្ធិអំណាចក្នុងការសម្រេចចិត្ត

-វត្ថុធាតុដើមភាគច្រើន គឺពួកគាត់អាចរកបាននៅក្នុងភូមិ-ស្រុក ដោយមិនបាច់ត្រូវធ្វើដំណើរទៅរកទិញឆ្ងាយពីផ្ទះ

-ផ្តល់ជាអាហារសម្រាប់រូបគាត់ និងគ្រួសារ ដោយកាត់បន្ថយការចំណាយបានមួយចំនួនលើចំណីអាហារ

*បុរសនិងស្ត្រីសុទ្ធតែបានតួនាទីក្នុងការងារចិញ្ចឹមមាន់ដូចគ្នា វាផ្តល់ឱ្យពួកគាត់នូវឱកាស ក្នុងការចូលរួមធ្វើផែនការ និងបំពេញការងាររួមគ្នា ដើម្បីធ្វើឱ្យប្រសើរឡើង នូវទំនាក់ទំនងជាមួយគ្នា និងការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា*



# ការសាងសង់ទ្រុង និងរបងជុំវិញទ្រុង

**ហេតុផលនៃការចិញ្ចឹមមាន់ដោយដាក់ទ្រុងនិងក្នុងរបង:**

- ការពារមាន់ពីសត្វសាហាវផ្សេងៗ អាកាសធាតុ និងចោរលួច......
- ងាយស្រួលថែទាំ ផ្តល់ចំណី ចាក់ថ្នាំការពារ-ព្យាបាល និងតាមដានសកម្មភាពរបស់មាន់
- ងាយស្រួលក្នុងការគ្រប់គ្រង(កូនមាន់ មេមាន់ពង មាន់ធំផ្សេងៗទៀត និងមាន់ទើបបកដល់ថ្មី)
- ការពារមនុស្សពីការឆ្លងជំងឺពីសត្វមាន់
- ងាយស្រួលក្នុងការចាប់លក់ និងទទួលទាន

# ការណែនាំក្នុងការសាងសង់ទ្រុង និងជម្រកឱ្យមាន់



ទ្រុងត្រូវសង់លើទីទួលបិនបិចទឹក និងបិនជាំទឹក មានជញ្ជាំងដែលអាចឱ្យខ្យល់ចេញចូលបានល្អ និងរបាំងការពារខ្យល់ ឬភ្លៀងខ្លាំង



ត្រូវសង់ទ្រុងនៅជិតផ្ទះ ដើម្បីងាយស្រួលតាមដាន



សង់ទ្រុងបណ្តោយពន្លឺ
ថ្ងៃ



-មានទីធ្លាខាងក្រៅទ្រុងឱ្យ
មាន់ដើរ

-មានប្លប់ឈើគ្រប់គ្រាន់

# ប្រភេទទ្រុង



**ទ្រុងប្រភេទនេះ៖**

- ងាយស្រួលសាងសង់ និងចំណាយតិច
- សមស្របសម្រាប់តំបន់ដែលមិនលិចទឹក ឬជោគជាំនៅរដូវវស្សា
- សម្រាប់គ្រួសារដែលមានទីធ្លាតូច ឬសមល្មម



**ទ្រុងប្រភេទនេះ**

- សបស្រួបសម្រាប់តំបន់ លិចទឹក ឬជោគជាំ និងមិនលិចទឹក
- សបស្រួបសម្រាប់ទីធ្លាតូច សបល្អប និងទូលាយ
- សបស្រួបសម្រាប់ការចិញ្ចឹមទ្រង់ទ្រាយធំ(ឧទា:ការចិញ្ចឹមមាន់យកសាច់)
- ងាយស្រួលធ្វើអនាម័យ
- ប៉ុន្តែចំណាយច្រើនជាងប្រភេទខាងលើបន្តិច

គេត្រូវក្រុងកូនមាន់ទើបញាស់ជាមួយមេ ឬបំបែកពីមេរបស់វា (ដោយផ្តល់ចំណីឱ្យវាបានគ្រប់គ្រាន់) ឱ្យបាន ១ខែ៖

<u>មូលហេតុគឺដើម្បី៖</u>

- ងាយស្រួលក្នុងការថែទាំសុខភាពកូនមាន់
- ងាយស្រួលក្នុងការចាក់ថ្នាំការពារ
- ការពារកូនមាន់ពីគ្រោះថ្នាក់ ដែលបង្កឡើងដោយសត្វផ្សេងៗ ទៀត ឬជំងឺឆ្លងពីមាន់ផ្សេងៗទៀត





**<u>ចំណាំ៖</u>** គេក៏អាចប្រើទ្រុងប្រភេទនេះសម្រាប់បំបែកមាន់ឈឺពីមាន់ជា

ការបំបែកកូនពីមេ:

-ផ្តល់ចំណី-ទឹក និងកំដៅឱ្យកូនមាន់បានគ្រប់គ្រាន់ (ប្រើអំពូលភ្លើង ឬឆ្នាំងដីដែលមានដាក់ធ្យូងដុត)

-ការពារកូនមាន់ពីខ្យល់បក់ខ្លាំង

-ក្រាលកំរាលឱ្យវាដេក ដោយប្រើអង្កាម និងចំបើង





ប្រើចំបើង អង្កាប ឬស្លឹកឈើស្ងួត ក្រាលនៅក្នុងទ្រុងដើម្បីឱ្យវាជួយបឺតយកសំណើប និងបង្កើតជាសត្វល្អិត ឬដង្កូវសម្រាប់ជាចំណីមាន់។



☞ ក្នុងទ្រុងត្រូវបានធ្វើសម្រាប់មាន់ដេក និងសំបុកឱ្យបេមាន់ពង

☞ ត្រូវរៀបចំជណ្ដើរសម្រាប់ឱ្យមាន់អាចឡើងដេក ឬឡើងក្រាបពងបានស្រួល



☞ បានបបន្ទប់មាន់ពង



☞ រៀបចំសំបុកសម្រាប់មេមាន់ពង (ប្រើកែស ក្រដាស ល្អី កន្ត្រក ជាល ឬដូចរូប ។ល។)

**<u>កំណត់សំគាល់</u>:** ចំនួនមាន់ក្នុងទ្រុង: ១០ក្បាល/ម$^{២}$

## ការផលិតស្នូកចំណី-ទឹកដោយខ្លួនឯង

### ការធ្វើស្នូកចំណីសម្រាប់ហាន់ធំ **អំពីឈើ**







**ការធ្វើស្នូកចំណីពីសំភារៈចាស់ៗ** ដូចជា ប៊ីដុង ធុងស្តេត្រូ (លាងស្អាត) និងកាធុន ឬចាន ដែកចាស់ៗ។ល។ (សម្រាប់ហាន់ធំ)

-យកធុងជ័រ ឬប៊ីដុងចាស់ៗ បកចោះរន្ធ ៤-៥ កន្លែងនៅគែបនៃបាតរបស់វា

-ដាក់វាពីលើកាធុន ឬចានដែកចាស់ៗ

-ទើបដាក់ចំណីចូល



ធ្វើស្នូកចំណីសម្រាប់កូនមាន់ **ពីបំពង់ឫស្សី ឬបំពង់ផ្សេងៗទៀត:**

-យកឫស្សី ឬបំពង់ផ្សេងៗទៀត បកឆ្កៀលឱ្យចេញជារន្ធចង្អូរ

-រួចយកកងលួសបកស៊កបញ្ចូល ហើយរឹតឱ្យតឹង

-គេអាចចងព្យួរវាក៏បាន ឬដាក់ផ្ទាល់នឹងកំរាល។






រាល់សំភារៈទាំងអស់ត្រូវតែស្អាតមានអនាម័យ!!!



ការចងព្យួរស្នូកចំណី-ទឹកក្នុងទ្រុង សម្រាប់មាន់ចំនួនច្រើន

## ការផលិតស្នូកទឹក

-ធ្វើស្នូកទឹកឱ្យមាន់ដោយប្រើប្រាស់ ដបចាស់ៗ ចានគ្រលោប ឬកាផុនតូចៗចាស់ៗ ឬផ្ដិលចាស់ៗ ឬសំភារៈផ្សេងៗទៀត។

-ករណីប្រើដប ត្រូវធ្វើយ៉ាងណារក្សាលំនឹងវាឱ្យបាន។

-គួរតែធ្វើស្នូកទឹកដែលអាចការពារកូនមាន់មិនឱ្យលង់ទឹកស្លាប់។







# ការជ្រើសរើសពូជ



**សារៈសំខាន់នៃការជ្រើសរើសពូជ**

-ពូជមាន់ល្អៗផ្តល់ផលចំណេញ អាចលក់បានក្នុងតម្លៃខ្ពស់។

-មាន់ដែលលូតលាស់ល្អ មានសុខភាពល្អ ធំលឿន ធន់នឹងបរិស្ថានក្នុងស្រុក ឆ្លើយតបតម្រូវការទីផ្សារក្នុងស្រុក។

-អាចឱ្យយើងរក្សាទុកនូវមេ-បាពូជមួយចំនួន សម្រាប់ចិញ្ចឹមបន្តទៅថ្ងៃខាងមុខ។

## លក្ខណៈសំគាល់ពូជមាន់ដែលល្អ



១. រូបរាងធំ ខ្ពស់សង្ហារ

២. រហ័សរហួន និងលូតលាស់ល្អ

៣. សុខភាពល្អ រោម និងស្រកាជើងភ្លឺរលោង

៤. ទឹកមុខស្រស់ថ្លា (មុខ សិរ និងណង់ក្រហមថ្លា មិនស្លេក ឬមិនស្រអាប់)

៥. ចំពោះមាន់ឈ្មោល គឺគ្មានស្នាមជាំលើក្បាល និងណង់ គឺត្រូវមានពណ៌ក្រហមថ្លា

៦. ភ្នែកភ្លឺថ្លា

៧. ចំពោះមាន់មេគឺត្រូវមានត្រគាកសាយ ដោយប្រើប្រាប់ដៃពិនិត្យមើលដូចខាងក្រោម៖



គុម្ពកន្ទុយអាចដាក់ប្រាប់ដៃបានបីល្មម (មេមាន់ល្អ គួរទុកបន្តពូជ)



គុម្ពកន្ទុយដាក់ប្រាប់បានតែ ២ធ្នាប់ (មិនគួរទុកបន្តពូជ)

# លក្ខណៈសំគាល់មាន់ឈឺៈ



រោមស្លូត ស្រអាប់ ហើយបះ




សិររបស់វាឡើងហើប



សិរ និងបុខឡើងក្រហមជាំ

មានពពឹកភ្នែក

**ក្នុងការទិញមាន់មកចិញ្ចឹម យកល្អគួរទិញមាន់ពូជក្នុងស្រុក ពីព្រោះៈ**

- វាធន់នឹងបរិយាកាសក្នុងស្រុក និងជម្ងឺ
- វាស៊ីចំណីដែលរកបានក្នុងបូលដ្ឋានបានល្អ
- សមស្របសម្រាប់ការចិញ្ចឹមបជាលក្ខណៈគ្រួសារ

## ការដឹកជញ្ជូនមាន់មកចិញ្ចឹម

- កសិករគួររកទិញមាន់ធំប្រសើរជាងទិញកូនមាន់មកចិញ្ចឹម
- ក្នុងពេលដឹកជញ្ជូនសូមកុំដាក់មាន់ក្នុងទ្រុងតែមួយច្រើនពេកពីព្រោះវាអាចជាន់គ្នាបណ្តាលឱ្យងាប់
- ចៀសវាងការចងមាន់ព្យួរជើង
- ទ្រុងសម្រាប់ដឹកត្រូវឱ្យមានខ្យល់ចេញចូល និងកុំឱ្យមាន់ប៉ះទង្គិចនឹងខ្យល់ខ្លាំងពេក

**មិនមែនដូចនេះ**





## ពេលដឹកមកដល់

-បង្ខាំងមាន់ទើបមកដល់ថ្មីឱ្យនៅដាច់ពីមាន់ដែលមានស្រាប់ ក្នុងទ្រុងមួយដាច់ដោយឡែក ដើម្បីតាមដានរកមើលជម្ងឺ

-ក្រោយពីដឹកមកដល់បាន១ម៉ោង គឺត្រូវផ្ដល់ទឹកដែលមានលាយជាមួយវីតាមីនឬស្ករ ឱ្យមាន់ផឹក








## ចំណីសម្រាប់មាន់

### ប្រភេទចំណីសម្រាប់ផ្តល់ឱ្យមាន់

-ពោត ស្រូវ កន្ទក់ ចុងអង្ករ បាយក្រៀប និង បាយក្តាំង កាកសំណល់ផ្ទះបាយ សណ្តែក កណ្តៀរ កំពិស និង កូនត្រីល្អិត

-ស្លឹកបន ចក កំប្លោក ត្រកួន ជន្លេន សត្វល្អិត ផ្សិត ស្លឹកបាស ស្លឹកប្រំ ស្លឹកដំឡូងបី ដំឡូងជ្វា (ទង ស្លឹក និង មើម) ត្រាវ (មើម និង ធាង) ក្បាលត្រី....

### ការផ្តល់ចំណីឱ្យមាន់

-ចំណីដែលល្អត្រូវបានធាតុផ្សំ ២-៣មុខ ដូចជា រុក្ខជាតិ គ្រាប់ធញ្ញជាតិ និងសត្វ

-ត្រូវផ្តល់ឱ្យមាន់យូរៗម្តង នូវសារធាតុសំយោគដែលចាំបាច់ ទៅក្នុងចំណី ដូចជា ម្រេចបុក និង អំបិល

*មាន់ត្រូវការទឹកស្អាត និងមានអនាម័យសម្រាប់ផឹកគ្រប់គ្រាន់!*



*កុំភ្លេចសម្អាតស្នូកចំណី-ទឹកឱ្យបានទៀងរាល់ថ្ងៃដើម្បីចៀសវាងការកើតជម្ងឺផ្សេងៗ !*




 លាយចំណីចូលគ្នាបុនឱ្យមាន់ស៊ី!



**ជំនួយស្មារតី: របៀបទុកដាក់ចំណីមាន់រយៈពេល ១-២ ខែ**

- រក្សាទុកដាក់ចំណីក្នុងថង់ ឬសំភារៈផ្សេងៗ ឱ្យផុតពីទឹក
- ប្រើប្រាស់ទប្រសប្រាប់ទ្រថង់ឬសំភារៈទុកចំណីនោះឱ្យផុតពី ក្របាល ឥដ្ឋ ឬផ្ទៃបន្ទប់
- រក្សាវាទុកក្នុងកន្លែងដែលស្ងួត ប៉ុន្តែត្រូវឱ្យបានខ្យល់និងពន្លឺគ្រប់គ្រាន់
- ការពារការបំផ្លាញដោយសត្វកកេរ

## កម្រិតបរិមាណចំណីដែលត្រូវផ្សំសម្រាប់មាន់៖




១. ការឱ្យចំណីកូនមាន់៖ ចាប់ពីញាស់របួតដល់អាយុពសប្ដាហ៍

| លរ | សមាធាតុចំណីដែលត្រូវផ្សំ | ជំរើសទី១ | ជំរើសទី២ | ជំរើសទី៣ |
|---|---|---|---|---|
| ១ | កន្ទក់ | ៣ គក | ៣ គក | ៣ គក |
| ២ | ចុងអង្ករ | ៣ គក | ៣ គក | ៣ គក |
| ៣ | ម្សៅត្រី | ១ គក | | |
| ៤ | ជន្លេន | | ១.៥ គក | ១ គក |
| ៥ | កណ្ដៀរឈើ | | | 0.៥ គក |
| ៦ | ម្សៅពោតក្រហម | ១ គក | ២ គក | ២ គក |
| ៧ | ម្សៅសណ្ដែកសៀង(លីង) | ២ គក | | |
| ៨ | ស្លឹកប្រុំ | | 0.៥ គក | 0.៥ គក |
| ៩ | អំបិល | 0.0៥ គក | 0.0៥ គក | 0.0៥ គក |
| ១០ | ម្រេចបិច | 0.0៥ គក | 0.0៥ គក | 0.0៥ គក |
| សរុប | | ១០ គក | ១០ គក | ១០ គក |

**បរិមាណផ្ដល់ឱ្យ៖ ៣០-៧០ ក្រាម ក្នុងកូនមាន់មួយក្បាល ក្នុងមួយថ្ងៃ**

២. ការឱ្យចំណីមាន់ធំ



| លរ | សមាធាតុចំណីដែលត្រូវផ្សំ | ជម្រើសទី១ | ជម្រើសទី២ | ជម្រើសទី៣ |
|---|---|---|---|---|
| ១ | កន្ទក់ | ៣ គក | ៣ គក | ៤ គក |
| ២ | ចុងអង្ករ | ២ គក | ១ គក | |
| ៣ | ប្រស្រ្តី ត្រីក្រៀប ក្បាលត្រី ឬកំពិស | ១ គក | 0.៥ គក | |
| ៤ | ជន្លេន | | 0.៥ គក | 0.៧ គក |
| ៥ | កណ្តៀរឈើ | | | 0.៣ គក |
| ៦ | ពោតក្រហម | ២ គក | ២.៥ | ៣ គក |
| ៧ | សណ្តែកសៀង ឬ សណ្តែកបាយ | ១ គក | 0.៥ | |
| ៨ | ស្លឹកកន្ធំថេត ដំឡូងបី ប្រហែលក្រៀប | ១ គក | ១ គក | ១ គក |
| ៩ | ចកបាយទា | | ១ គក | ១ គក |
| ១០ | អំបិល | 0.0៥ គក | 0.0៥ គក | 0.0៥ គក |
| ១១ | ព្រៃបិច | 0.0៥ គក | 0.0៥ គក | 0.0៥ គក |
| សរុប | | ១០ គក | ១០ គក | ១០ គក |

**បរិមាណផ្តល់ឱ្យ: ៧០-២០០ ក្រាម ក្នុងមាន់មួយក្បាល ក្នុងមួយថ្ងៃ**

## ៣. ការឱ្យចំណីមាន់ពង



| លរ | សមាសធាតុចំណីដែលត្រូវលាយ | ជម្រើសទី១ | ជម្រើសទី២ | ជម្រើសទី៣ |
|---|---|---|---|---|
| ១ | កន្ទក់ | ៣ គក | ៣ គក | ២ គក |
| ២ | ចុងអង្ករ | ១ គក | ១ គក | ១ គក |
| ៣ | ប្រហុក ត្រី ត្រីក្រៀម ក្បាលត្រី ឬកំពិស | ១ គក | | |
| ៤ | ជន្លេន | | ១ គក | ១ គក |
| ៥ | កណ្តៀរឈើ | | | ០.៥ គក |
| ៦ | ពោតក្រហម | ៣ គក | ២ គក | ២ គក |
| ៧ | សណ្តែកសៀង ឬសណ្តែកបាយ | | | ០.៥ គក |
| ៨ | ប្រភេទស្លឹកក្រៀម (កន្ធំថេត ដំឡូងបារាំង ប្រាំ) | ១ គក | ១ គក | ១ គក |
| ៩ | ចកបាយទា | ១ គក | ២ គក | ២ គក |
| ១០ | សំបកខ្យង ខ្ចៅ គ្រុំ | ០.១ គក | ០.១ គក | ០.១ គក |
| ១១ | អំបិល | ០.០៥ គក | ០.០៥ គក | ០.០៥ គក |
| ១២ | ម្រេចបិច | ០.០៥ គក | ០.០៥ គក | ០.០៥ គក |
| សរុប | | ១០ គក | ១០ គក | ១០ គក |

**បរិមាណផ្តល់ឱ្យ: ៧០-១០០ ក្រាម ក្នុងមាន់មួយក្បាល ក្នុងមួយថ្ងៃ**

**សំគាល់:** គួរផ្តល់ឱ្យកូនមាន់នូវចំណីផ្សំកិនម៉ដ្ឋ ក្នុងរយៈពេល២សប្តាហ៍ដំបូង រួចហើយផ្លាស់ប្តូរវា ទៅជាចំណីអាហារធម្មតាបន្តិចម្តងៗរៀងរាល់ថ្ងៃ រហូតទាល់តែអាចឱ្យវាស៊ីចំណីធម្មតាទាំងស្រុងបាន។

**សំគាល់:** ចំពោះជន្លេន និងត្រីក្រៀប ឬ បង្គាត្រី គឺអាចប្រើប្រាស់ផ្លាស់ប្តូរគ្នាបាន: ប្រសិនបើប្រើមួយត្រូវអត់មួយ ឬកាត់បន្ថយបង្គាត្រី ដោយប្រើជន្លេនខ្លះ

**សំគាល់:** ចំពោះសំបកខ្យង-ខ្ចៅ គួរឱ្យម៉ដ្ឋសម្រាប់លាយជាមួយរូបធាតុចំណីផ្សេងៗទៀត



# ការផលិតចំណីឱ្យមានដោយខ្លួនឯង

## ក. ការផលិតចកបាយទា

ក១. <u>រៀបចំ</u>

១. ជីករណ្តៅ ទំហំ២ម x ៣ម និង ជម្រៅពី ០.៣ម ទៅ ០.៤ម (ទំហំអាចប្រែប្រួលបានតាមស្ថានភាព ឬទំហំដីរបស់កសិករ)

២. ក្រាលថង់ប្លាស្ទិកនៅបាតរណ្តៅ

៣. បញ្ចូលទឹកជម្រៅចាប់ពី០.២ម ទៅ ០.៣ម

៤. ដាក់លាមកគោ ឬលាមកជ្រូកលាយជាមួយទឹករួចចាក់ចូលក្នុងរណ្តៅ

៥. ចាក់ពូជចកបាយទាចំនួន១គកចូលទៅក្នុងរណ្តៅ

ក២. <u>ការប្រើវាសម្រាប់ធ្វើជាចំណីមាន់</u>

១. ដងចកបាយទាពីស្រះបកសំដិលឱ្យវាស្រពាប់ (ឱ្យស្រក់ទឹកអស់)

២. យកវាមកលាយកន្ទក់ ឬ ចុងអង្ករ រួចបាចឱ្យមានឱ្យស៊ី





## ខ. ការដាំមន និងស្លឹកប្រមំសម្រាប់ធ្វើចំណីមាន់

### ១.ដើមមន

### ១.១ ការរៀបចំ

កសិករអាចយកបែកបន ដែលមានសុខភាពល្អបកដាំនៅជុំវិញរបងផ្ទះ ហើយស្រោចទឹកវាជាទៀងទាត់

 

### ១.២ ការប្រើប្រាស់

- ប្រើស្ងួត ឬស្រស់
- ប្រើលាយជាមួយកន្ទក់ ចុងអង្ករ ឬ វត្ថុធាតុដើមផ្សេងៗទៀត
- ស្លឹកស្រស់គេអាចចិញ្ច្រាំ និងបន្ថែមទៅក្នុងចំណីផ្សំឱ្យមាន់ស៊ុយក តែប្តូង
- ស្លឹកស្ងួតគេអាចប្រើប្រាស់នៅពេលណាក៏បាន
- ការប្រើស្លឹកប្រមំគេមិនគួរប្រើលើសពី១០% នៃបរិមាណចំណីសរុប ឡើយ

## ២. ដើមម្រុំ

### ២.១ ការរៀបចំ

កសិករអាចយកគ្រាប់បកបាចតាមរបងផ្ទះ ឬអាចបណ្តុះក្នុងថ្នាលរួចយកទៅដាំតាមរបងផ្ទះ ឬកន្លែងដីទំនេរដែលកសិករគិតថាអាចដាំបាន។





### ២.២ ការប្រើប្រាស់

- ប្រើស្ងួត ឬ ស្រស់
- ប្រើលាយជាមួយកន្ទក់ ចុងអង្ករ ឬ វត្ថុធាតុដើមផ្សេងៗទៀត
- ស្លឹកស្រស់គេអាចចិញ្ច្រាំ និងបន្ថែមទៅក្នុងចំណីផ្សំឱ្យមាន់ស៊ីយកតែបុង
- ស្លឹកស្ងួតគេអាចប្រើប្រាស់នៅពេលណាក៏បាន
- ការប្រើស្លឹកប្រុំគេមិនគួរប្រើលើសពី១០% នៃបរិមាណចំណីសរុបឡើយ

## គ. ស្លឹកដំឡូងមី:

### គ១. ការរៀបចំ

កសិករអាចប្រមូលវាមកហាលឱ្យស្ងួតហើយច្រកបាវទុកសម្រាប់ឱ្យមាន់ស៊ីក្នុងបរិមាណបួយតិចតួច។





### គ២. ការប្រើប្រាស់

- គេអាចប្រើបានតែស្លឹកស្ងួតប៉ុណ្ណោះ
- ប្រើលាយជាមួយកន្ទក់ ចុងអង្ករ ឬ វត្ថុធាតុដើមផ្សេងៗទៀត
- មិនត្រូវប្រើវាលើសពី ១០% នៃបរិមាណចំណីសរុបឡើយ

## ឃ. ដើម និង ស្លឹកដំឡូងជ្វា ត្រកួន ស្ពៃ ស្លឹកបាស និង ផ្ទីរ

ឃ១. ការប្រើប្រាស់៖

១. ចិញ្ច្រាំ ឬហាន់វាឱ្យល្អិត

២. លាយជាមួយចំណីផ្សេងៗទៀត

៣. អាចប្រើប្រាស់វារហូតដល់ទៅ ១០-១៥% នៃបរិមាណចំណីសរុប

៤. គេអាចស្ងោរវាឱ្យបាន់ស៊ីក៏បាន

*នេះជារូបភាពស្លឹកនិងដើបដំឡូងជ្វា និងត្រកួន*









## ៥. ការចិញ្ចឹមជន្លេន

### ៥១. ការរៀបចំ

១. ជីករណ្ដៅលើដីដែលមិនលិចទឹកក្នុងជម្រៅពី០.៣ម ទៅ ០.៤ម ឬ អាចប្រើផើង ឬពាងចាស់ៗ

២. ក្រាលថង់ផ្លាស្ទីនៅបាតរណ្ដៅ ឬអាចពាសស៊ីម៉ង់ដើម្បីកុំឱ្យជន្លេនចាក់ចូលទៅក្នុងដី

៣. ដាក់កំប៉ុស្តធ្វើអំពីលាមកគោ (ស្ងួត ឬសើម) លាយជាមួយកំទេចកំទីរុក្ខជាតិ

៤. ដាក់ដីដែលមានជន្លេន (ពូជជន្លេន)

៥. ដាក់កំប៉ុស្តធ្វើអំពីលាមកគោ (ស្ងួត ឬសើម) លាយជាមួយកំទេចកំទីរុក្ខជាតិ

៦. ស្រោចទឹកសើមៗជានិច្ច តែមិនឱ្យសើមជោគទេ

៧. យកស្លឹកត្នោត ឬថង់ប្លាស្ទិកមកគ្របជាដំបូលរណ្ដៅ



ថ្នាលចិញ្ចឹមជន្លេន



## ៦២. ការប្រើប្រាស់

១. យកវាបកឱ្យមាន់ស៊ី ក្រោយពីចិញ្ចឹមបាន ៤០-៤៥ថ្ងៃ

២. យកចប ឬ ស្លាបព្រាបាយអរបកចូកកំប៉ុស្ត

៣. ដាក់ហាលថ្ងៃ ហើយត្រសុសដីចេញ

៤. ចិញ្ច្រាំវាឱ្យមាន់ស៊ី ឬ អាចលាយជាមួយធាតុផ្សំផ្សេងៗ(កន្ទក់ ស្រូវ ចុង អង្ករ...)

៥. រៀបចំកំប៉ុស្តថ្មីដើម្បីដាក់បំពេញនៅកន្លែងដែលយើងគាស់ឱ្យមាន់ស៊ី

## ច. អន្ទាក់សត្វល្អិត

### ច១. ការរៀបចំ

យើងធ្វើដូចគ្នានឹងការចិញ្ចឹមជន្លេនដែរ តែគ្រាន់តែមិនយកថង់ផ្លាស្ទិក ទៅទ្រាប់បាតរណ្ដៅឡើយ

១. ធ្វើជាកំប៉ុស្តដោយផ្សំពីលាមកសត្វ និង កំទេចរុក្ខជាតិ

២. យកសំបុកកណ្ដៀរស៊ីឈើមកបំបែកហើយដាក់ចូលទៅក្នុងកំប៉ុស្ត

៣. ធ្វើរបងបាំង និងគ្របដោយបែកឈើ ឬបន្លាឫស្សីមកគ្រប

៤. ស្រោចទឹកសើបៗជាប្រចាំ

៥. រៀបចំឱ្យបានច្រើនកន្លែងផ្សេងៗគ្នាក្នុងរបងដែលព័ទ្ធឱ្យមាន់ដើរ



### ច២. ការប្រើប្រាស់:

១. បើកគម្រប ឬបន្លាចេញ ដើម្បីឱ្យមាន់ចូលស៊ី

២. រៀបចំ និងថែបកំប៉ុស្តថ្មី



**ផលប៉ះពាល់ចំពោះផលិតកម្ម និង សុខុមាលភាព**

-ផលិតកម្មធ្លាក់ចុះ

-មាន់/បក្សីឈឺ និង ងាប់រង្គាល

-ការឆ្លងរីករាលដាលនៃជម្ងឺក្នុងហ្វូងមាន់/បក្សី ឬលើសត្វចិញ្ចឹមផ្សេងៗទៀត ពីតំបន់មួយទៅតំបន់មួយ

-ការឆ្លងជម្ងឺបក្សីលើមនុស្ស

-ខាតបង់ថវិកា ប្រាក់ចំណូល និងស្បៀង សម្រាប់ គ្រួសារនៅជនបទ

-ប៉ះពាល់ដល់ការធ្វើចរាចរ និង លក់ដូរផលិតផលមាន់ ក្នុងតំបន់/ភូមិ-ស្រុក (ត្រូវផ្អាក ឬហាមឃាត់)

១. ជំងឺញូវកាស (ជំងឺដង្កោកាច់)

**ការបង្កជំងឺ:**

- បង្កឡើងដោយមេរោគវីរុស
- កើតលើមាន់ទូទៅ ជាពិសេសនៅលើកូនមាន់ និងមាន់ជំទង់
- ឆ្លងតាមរយៈការរស់នៅឡូកឡំគ្នា (តាមចំណីអាហារ ទឹកផឹក ទឹករំអិល សំបោរ កំហាក លាមក សំភារៈប្រើប្រាស់ និងតាមរយៈភ្នាក់ងារចម្លងផ្សេងៗទៀត)។

**រោគសញ្ញា:**



- ខ្សោយ សំកុក ធ្លាក់ស្លាប ឈរម្នាក់ឯង ឬជាក្រុប (ករណីឈឺ ច្រើនក្បាល)
- មិនសូវស៊ីចំណី ឬមិនស៊ីតែម្តង
- ឡើងកំដៅក្នុងខ្លួន ផឹកទឹកច្រើន
- ដំបូងរាគខៀវមានក្លិនឆ្អួលឆ្អេះបន្ទាប់មកលាមកប្រែជារាវងសដូចកំបោរ
- ឈរមិននឹង ញ័រញាក់ កន្ត្រាក់ខ្លួន វង្វេលក



- មិនពង ឬពងតិច (ពងមានរាងខុសពីធម្មតា សំបកទន់ឬអត់សំបក សស៊ុតរាវ)
- ដកដង្ហើមស្អកខ្លីៗ
- អត្រាងាប់ខ្ពស់ តែមានឱកាសជាដោយឯកឯង

**ការការពារ:**

- ការពារបានតាមរយៈការចាក់ថ្នាំការពារ
- បំបែកសត្វឈឺចេញពីសត្វជា នៅពេលដែលជម្ងឺផ្ទុះឡើង
- សំអាតទ្រុងឡើងវិញដោយប្រើកំបោរស
- ជម្ងឺនេះគ្មានថ្នាំព្យាបាលទេ

២. ជម្ងឺអាសន្នរោគមាន់

**ការបង្កជម្ងឺ:**

- បង្កឡើងដោយបេរោគបាក់តេរី
- ហើយកើតលើមាន់ទូទៅ និងបក្សីផ្សេងៗទៀត
- វាឆ្លងតាមរយៈការរស់នៅឡូកឡំគ្នា

**រោគសញ្ញា:**

ករណីធ្ងន់ធ្ងរ: មាន់ងាប់ដោយគ្មានមូលហេតុឬរោគសញ្ញាច្បាស់លាស់ក្នុងរយៈពេល ២៤ ម៉ោង

ករណីបធ្យប



- មាន់ឡើងកំដៅ សំកុក
- អត់ផឹក អត់ស៊ី
- សិរជាំ ចេញទឹករំអិលនៅចំពុះនិងច្រមុះ
- ពិបាកដកដង្ហើម
- ជុះច្រើន លាមកមានពណ៌លឿងព្រលែត គួចប្រឡាក់លាមកជុំវិញ (អូសបន្លាយ ១-៣ថ្ងៃ)



- មាន់ងាប់

<u>ករណីស្រាល (អូសបន្លាយយូរ)</u>

- ហាន់រលាកភ្នែក ច្រមុះ
- រលាកត្រចៀក (ចេញទឹកពណ៌លឿងព្រលែតខាប់) ហាន់កាច់ក ទៅខាងត្រចៀករលាក
- ដើរលែងរួច និងធ្លាក់ស្លាប (រលាកសន្លាក់)
- ហាន់អាចងាប់

<u>ការការពារ</u>

តាមបែបបុរាណ:

- ខ្ទឹមស ០,៣ គីឡូក្រាម ខ្ញី ០,៥ គីឡូក្រាម ស្ករត្នោត ០,៣ គីឡូក្រាម
- យកខ្ញីនិងខ្ទឹមបុកចូលគ្នា
- ផ្អាប់ជាមួយស្ករត្នោតទុករយៈពេលកន្លះខែ
- ទើបយកបកបញ្ចុកហាន់ ១ សេសេ ក្នុងមួយក្បាល

*(សម្រាប់ការពារ បទពិសោធន៍កសិករឈ្មោះ **ប៊ុន អុល** នៅភូមិព្រៃជ្រូវ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ទូរស័ព្ទ: ០៨៩ ៩០០ ៩៨៨)។*

តាមបែបបច្ចេកទេស

- ចាក់ថ្នាំការពារ
- អនាម័យទ្រុង និងសម្ភារៈប្រើប្រាស់សម្រាប់ចិញ្ចឹម
- បំបែកសត្វឈឺចេញពីសត្វជារួចសម្លាប់ ហើយកប់ឬដុតចោល
- ផ្តល់ចំនី និងទឹកស្អាតគ្រប់គ្រាន់ដល់មាន់

៣. ជម្ងឺផ្តាសាយបក្សី៖

**ការបង្កជម្ងឺ៖**

- បង្កឡើងដោយវីរុស($H_5N_1$) លើមាន់ និងសត្វស្លាបផ្សេងៗទៀត
- វាឆ្លងតាមរយៈការរស់នៅឡូកឡំគ្នា (តាមចំណីអាហារ ទឹកផឹក ទឹករំអិល សំបោរ កំហាក លាមក) តាមរយៈសំភារៈប្រើប្រាស់ បធ្យោបាយដឹកជញ្ជូន អ្នកចិញ្ចឹមសត្វ និងភ្នាក់ងារចម្លងផ្សេងៗទៀត
- ធ្វើឱ្យមាន់ងាប់ច្រើន និងអាចឆ្លងមកលើមនុស្សផងដែរ និងមាន អគ្រោះគ្រោះថ្នាក់ខ្ពស់។



**រោគសញ្ញា៖**

- សត្វមិនស៊ីចំណី សំកុក រោមស្រអាប់
- សីតុណ្ហភាពឡើង ផឹកទឹកច្រើន
- ក្បាល និងណង់ឡើងជាំខ្មៅនិងឡើងហើម
- ហើមសន្លាក់ជើង និងជាំស្មងជើង
- រាគ និងហៀរសំបោរ កណ្តាស់
- គែរមិនរលាយ
- សំបកស៊ុតទន់-ខូចទ្រង់ទ្រាយ ផលិតកម្មស៊ុតថយចុះ
- ងាប់ទាន់ហាន់ក្នុងចំនួនច្រើន គ្មានឱកាសនឹងជា

## ការការពារ:

មិនអាចព្យាបាលឱ្យជាបានទេ ប៉ុន្តែគេអាចការពារជម្ងឺនេះបានដោយ:

- ចាក់ថ្នាំការពារ
- អនាម័យទ្រុង និងសម្ភារៈប្រើប្រាស់សម្រាប់ចិញ្ចឹម
- ផ្ដល់ចំណី និងទឹកស្អាតគ្រប់គ្រាន់ដល់មាន់
- កុំបរិភោគមាន់ដែលឈឺងាប់
- សម្លាប់មាន់ក្នុងទ្រុងដែលមានមាន់ឈឺហើយកប់ឬដុតចោល
- ពាក់ម៉ាស ស្រោមដៃ រួចធ្វើអនាម័យដៃជើងឱ្យបានស្អាតក្រោយពីប៉ះពាល់មាន់ឈឺ ឬងាប់ ឬសំភារៈចិញ្ចឹម





ការប្រៀបធៀបជម្ងឺផ្តាសាយ និងជម្ងឺញូវកាស

| ជម្ងឺ | លក្ខណៈខុសគ្នា | លក្ខណៈដូចគ្នា |
| --- | --- | --- |
| ជម្ងឺញូវកាស | -ដំបូងរាគខៀវបានក្លិនឆ្អួលឆ្អេះ រួចប្រែជារឹងសដូចកំបោរ<br>-ឈរបិននឹង ញ័ញាក់ កន្ត្រាក់ខ្លួនរបួលក<br>-ដកដង្ហើមស្អកខ្លីៗ<br>-តែបានឱកាសជាដោយឯកឯង<br>-អត្រាងាប់ខ្ពស់ | -ខេ្សាយ សំកុក ធ្លាក់ស្លាប ឈរប្ចាក់ឯង ឬជាក្រុប (ករណីឈឺច្រើនក្បាល)<br>-មិនស្សូវស៊ី ឬមិនស៊ីតែម្តង<br>-ឡើងកំដៅខ្លួន ផឹកទឹកច្រើន<br>-រាគ ហៀរសំបោរ និងកណ្តាស់<br>-សំបកស៊ុតទន់ ខូចទ្រង់ទ្រាយ ផលិតកម្មស៊ុតថយចុះ |
| ផ្តាសាយបក្សី | -ក្បាលនិងណង់ជាំខ្មៅនិងហើប<br>-ហើបសន្លាក់ជើង និងជាំស្នងជើង<br>-គេរបិនរលាយ<br>-ងាប់លឿន គ្មានឱកាសនឹងជា | |

៤. <u>ជម្ងឺរាគស:</u>

**ការបង្កជម្ងឺ:**

- បង្កឡើងដោយបាក់តេរី
- វាច្រើនកើតនៅលើមាន់អាយុ១-១៥ថ្ងៃ អត្រាងាប់ពី ៤០-៥០%
- វាក៏កើតលើមាន់ធំផងដែរ ពិសេសមេមាន់ពង
- ចំពោះមនុស្សដែលបរិភោគស៊ុតឆៅ បានពីមេមាន់កើតជម្ងឺដែលអាច កើតជម្ងឺគ្រុនពោះវៀន

**រោគសញ្ញា:**

កូនមាន់អាយុ: ១-១៥ ថ្ងៃ

- សំកុក ស៊ីចំណីតិច ឬមិនស៊ី
- កូនមាន់ច្រើននៅផ្តុំគ្នាត្រង់កន្លែងមានកំដៅ
- ឡើងកំដៅ ផឹកទឹកច្រើន
- រាគលាមកពណ៌សស្រអាប់ ពោះធំ ចុះស្គម
- រោមបះ និងមានលាមកប្រឡាក់ជាប់គូទ
- កន្ត្រាក់ខ្លួន បត់ក្បាល រួចងាប់





ចំពោះបេហាន់ពង

- រាគ រោបស្រអាប់
- សិរស្លេកស្លាំង ចុះស្គម
- ពងតិច សំបកទន់ និងវៀចវ៉ៃ

**ការព្យាបាល:**

ជម្ងឺនេះ អាចព្យាបាលបានដោយប្រើឱសថធម្មជាតិ ដូចខាងក្រោម:

- ស្លឹកអង្កាញ់ ៣គីឡូក្រាម បុកពូតយកទឹក
- លាយជាមួយស្ករ ១គីឡូក្រាម
- ទុកចោលមួយអាទិត្យ
- យកបកលាយទឹក ១០ លីត្រ ដោយប្រើវា ១ស្លាបព្រាបាយ ដាក់ឱ្យមាន់ផឹក

(*បទពិសោធន៍កសិករ ឈ្មោះ* ***ប៊ុន អុល*** *នៅភូមិព្រៃជួរ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ទូរស័ព្ទ: ០៨៩ ៩០០ ៩៤៨*)។

**ការការពារ៖**

- ចាក់ថ្នាំការពារ
- អនាម័យទ្រុង(ជាប្រចាំ) ស្នូកចំណី ស្នូកទឹក(រាល់ថ្ងៃ)
- ផ្តល់កំដៅដល់កូនមាន់ (ប្រើអំពូលកំដៅ ឬដុតធ្យូងដាក់ក្នុងឆ្នាំងដីក្រាលអង្កាម)
- ផ្តល់ឱ្យមាន់នូវចំណីនិងទឹកមានគុណភាពល្អ
- ការពារការចម្លងពីសត្វផ្សេងៗ (ពិសេសសត្វកណ្តុរ)
- បំបែកមាន់ឈឺពីមាន់ជា
- ហាមទុកមាន់ដែលជាពីជម្ងឺនេះសម្រាប់ធ្វើពូជ

**ការការពារ:**

- ចាក់ថ្នាំការពារ
- អនាម័យទ្រុង(ជាប្រចាំ) ស្នូកចំណី ស្នូកទឹក(រាល់ថ្ងៃ)
- ផ្តល់កំដៅដល់កូនមាន់ (ប្រើអំពូលកំដៅ ឬដុតធ្យូងដាក់ក្នុងឆ្នាំងដីក្រាលអង្កាម)
- ផ្តល់ឱ្យមាន់នូវចំណីនិងទឹកមានគុណភាពល្អ
- ការពារការចូលពីសត្វផ្សេងៗ (ពិសេសសត្វកណ្តុរ)
- បំបែកមាន់ឈឺពីមាន់ជា
- ហាមទុកមាន់ដែលជាពីជប៊ីនេះសម្រាប់ធ្វើពូជ

៥. ជម្ងឺអុតបក្សី:

**ការបង្កជម្ងឺ:**

- បង្កឡើងដោយវីរុស
- វាកើតលើមាន់គ្រប់អាយុ ពិសេសលើកូនមាន់និងមាន់ជំទង់
- ភ្នាក់ងារចម្លងសំខាន់ របស់វាគឺមូស និងសត្វល្អិតជញ្ជក់ឈាមផ្សេងៗទៀត (ឧទាះសត្វ ល្បោប ចៃ ស្រមើល ដង្កែ...)
- វាក៏អាចឆ្លងតាប រយៈការប៉ះពាល់គ្នារវាងសត្វឈឺនិងសត្វជា

**រោគសញ្ញា:**

- មានដុំពក (ពងដោរមានទឹក រួចក្លាយជាក្រមរក្រៀម) នៅលើស្បែក និង កន្លែងដែលគ្មាន រោមផ្សេងៗទៀត ពិសេសនៅលើក្បាល ណង់ គូទ និងជើង
- ក្នុងសណ្ឋានជាខាន់ស្លាក់ ពិបាកដកដង្ហើម មានក្រមរបិទបាំងរន្ធច្រមុះ
- មាន់ឡើងពពឹកភ្នែក ខ្វាក់ភ្នែក
- ពិបាកស៊ីចំណី និង ផឹកទឹក
- មាន់លូតលាស់យឺត និង ផលិតកម្មស៊ុតថយចុះ





**ការព្យាបាលៈ**

- បុកប្រេចបញ្ចូកមាន់ឈឺ ២ដងក្នុងមួយថ្ងៃ រយៈពេល៣ថ្ងៃ(១គ្រាប់សម្រាប់កូនមាន់ និង ២-៣គ្រាប់ សម្រាប់មាន់ធំ) រួចលាបប្រេចលើបុខក្របរ
- បញ្ចូកគ្រាប់ម្ទេសទុំឱ្យសត្វមាន់ (កូនមាន់ និងមាន់ជំទង់២-៣គ្រាប់ មាន់ធំ ៥-១០គ្រាប់ ក្នុងមួយថ្ងៃ) រយៈពេល៣ថ្ងៃ។
- បុកស្លឹកអង្គ្រែងអង្គ្រង ១ទូកដៃ លាយជាមួយកំបោរក្រហម១ក្តាប់ដៃ លាបលើបុខក្របរ ក្នុងមួយថ្ងៃ៣ដង រយៈពេល៣ថ្ងៃ។

(*ដកស្រង់ចេញពីសៀវភៅ* ***ការចិញ្ចឹមមាន់*** *នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម ឆ្នាំ២០០៨*)

**ការការពារៈ**

- ចាក់ថ្នាំការពារ
- បំបែកមាន់ឈឺពីមាន់ជា រួចកំទេចចោល
- អនាម័យទ្រុង ស្នូកទឹក ស្នូកចំណី
- ការពារបូស (ដោយប្រើស្បៃធ្វើជាបុង កាប់ឆ្ការគុម្ពោតព្រៃដែលនៅក្បែរទ្រុង)
- បេះក្របរលើខ្លួនសត្វមាន់ រួចលាងកន្លែងរបួសឱ្យស្អាតដោយប្រើទឹកប្រៃ ឬទឹកអំបិល

៦. ព្រូនបូល:

## ការបង្កជម្ងឺ:

វាបង្កបញ្ហារាយខ្លាំងដល់សត្វមាន់ វាធ្វើឱ្យពោះវៀនរបស់មាន់របួស បញ្ចេញជាតិពុលធ្វើឱ្យមាន់ពុល ដែលងាយស្រួលឱ្យជម្ងឺផ្សេងៗទៀតរាតត្បាត។

## រោគសញ្ញា:



- ស្លេកស្លាំង រោមស្អួត
- ចុះស្គម បាក់កំលាំង
- មិនសូវស៊ីចំណី
- លូតលាស់យឺតឬមិនធំ
- រាគ ចុះទំងន់ ពងតិចនិងគុណភាពទាប
- លាមកមានព្រូន
- មាន់ងាប់

**ការការពារ**

- អនាម័យទ្រុង ស្តុកទឹក ស្តុកចំណី
- បំបែកសត្វឈឺចេញពីសត្វជា

**ការព្យាបាលៈ**

- បញ្ចុះព្រូនមាន់ឱ្យបានទៀងទាត់ (យកចំណិតស្លាខ្ចី ៣ក្រាប ឬគ្រាប់សង្កែរ ៣ក្រាប បុកលាយទឹកឱ្យមាន់ផឹកឬបញ្ជូកវា)



**កំណត់សំគាល់៖**

ប្រសិនបើករណីមានមាន់ឈឺ កសិករត្រូវការព្យាបាលសត្វមាន់របស់ខ្លួន ពួកគាត់អាចពិភាក្សា ឬទាក់ទងបសុពេទ្យ ឬភ្នាក់ងារសុខភាពសត្វភូមិ។

**សង្ខេប៖ វិធីសាស្ត្រការពារការឆ្លងជម្ងឺមាន់**

-ចាក់ថ្នាំការពារសុខភាពសត្វមាន់មិនទាន់ឈឺឱ្យបានទៀងទាត់

-ផ្តល់ចំណីនិងទឹកស្អាតដល់មាន់ឱ្យបានគ្រប់គ្រាន់

-ឧស្សាហ៍ធ្វើអនាម័យទ្រុងឱ្យបានញឹកញាប់ (រៀងរាល់សប្តាហ៍)

-បង្ការកុំឱ្យសត្វផ្សេងៗទៀត ចេញចូលក្នុងទ្រុងចិញ្ចឹមមាន់ (ដូចជា ឆ្កែ កណ្តុរ...)

-ហាមមនុស្សចំលែកចូលទ្រុងមាន់ ឬធ្វើការផ្លាស់ប្តូរសំលៀកបំពាក់ និងសំលាប់មេរោគលើស្បែកជើងជាមុន មុននឹងអនុញ្ញាតឱ្យចូលទ្រុងចិញ្ចឹម

-ធ្វើការសំអាតសំលាប់មេរោគលើសភារៈផ្សេងៗ ដែលត្រូវយកមកប្រើប្រាស់ចិញ្ចឹមមាន់ជាមុន មុននឹងប្រើប្រាស់វា

**សង្ខេប: វិធីសាស្ត្រការពារការឆ្លងជម្ងឺមាន់ (គ)**

-ត្រូវសង់ទ្រុងមាន់ឱ្យដាច់ពីលំនៅឋាន និងឆ្ងាយពីទ្រុងឬក្រោលសត្វផ្សេងៗទៀត (កុំចិញ្ចឹមសត្វឡូកឡំគ្នាក្នុងទ្រុងតែមួយ)

-បំបែកមាន់ឈឺចេញពីមាន់ជារួចកំទេចចោល

-សំលាប់មេរោគលើទ្រុងមាន់និងសំភារៈចិញ្ចឹមផ្សេងៗទៀត ដោយប្រើកំបោរស ឬទឹកកំបោរស

-ចិញ្ចឹមមាន់តូចឱ្យនៅដាច់ឆ្ងាយពីមាន់ធំ

-បង្ខាំងមាន់ដែលទើបបកដល់ថ្មីពីមាន់ផ្សេងៗទៀតរយៈពេលយ៉ាងតិច ១៨ថ្ងៃ មុននឹងឱ្យវាចូលជាមួយហ្វូងមាន់ផ្សេងៗទៀត

**ការណែនាំខ្លះៗអំពីការការពារការឆ្លងជម្ងឺមាន់ទៅលើមនុស្ស:**

- កុំបរិភោគសាច់ដែលបានពីមាន់ឈឺ ឬងាប់ដោយសារជម្ងឺ
- ដុត ឬកប់ចោលនូវសាកសពមាន់ដែលបានងាប់ដោយសារជម្ងឺក្នុងជម្រៅ ០,៥-១ម៉ែត្រ
- មិនត្រូវប៉ះពាល់សាកសព ឬកាកសំណល់មាន់ដែលឈឺស្លាប់ ដោយដៃទទេរនោះទេ ជាពិសេសសាកសពមាន់ស្លាប់ដោយជម្ងឺផ្តាសាយបក្សី
- ដុត ឬកប់ចោលនូវកាកសំណល់ទាំងអស់ដែលមាន រួចហើយសម្អាតដៃរបស់អ្នកនិងសំភារៈផ្សេងៗទៀត ដោយសាប៊ូ ឬរំងាប់មេរោគវាក្រោយពីសម្លាប់មាន់រួច
- ការពារកុមារកុំឱ្យចូលទៅជិតតំបន់ដែលមានផ្ទុះជម្ងឺ ឬប៉ះពាល់មាន់ងាប់ដោយជម្ងឺជាដាច់ខាត
- សម្អាតសំភារៈដែលប្រើប្រាស់សម្រាប់ចិញ្ចឹមមាន់
- បាចកំបោរស ឬទឹកកំបោរសនៅក្នុងនិងនៅលើទ្រុង
- ធ្វើទ្រុងមាន់ឱ្យនៅដាច់ពីលំនៅឋានរបស់មនុស្ស
- កុំធ្វើការវះកាត់សាកសពមាន់ដែលស្លាប់ដោយសារជម្ងឺ



## កម្មវិធីចាក់ថ្នាំការពារសុខភាពមាន់

| (ជម្រើស ១) (សមស្របសម្រាប់មាន់ពូជ) | | |
|---|---|---|
| **អាយុ (ថ្ងៃ)** | **វ៉ាក់សាំង** | **ការផ្តល់** |
| ៥ | ញូវកាស F ឬ B1 | បន្តក់ក្នុងភ្នែក ឬច្រមុះ * |
| ១០ | អុត | ជួសនៅស្បែកផ្ទាំងស្លាប |
| ២០ | ញូវកាស F ឬ B1 | បន្តក់ក្នុងភ្នែក ឬច្រមុះ |
| ៤០ | ញូវកាស La sota | លាយទឹកផឹក * |
| +៦០ | ញូវកាស M | ក្នុងសាច់ដុំ |

### (ជម្រើស ២) (សមស្របសម្រាប់មាន់លក់សាច់)

| អាយុ (ថ្ងៃ) | វ៉ាក់សាំង | ការផ្តល់ |
|---|---|---|
| ៥ | ញូកាស I2 | បន្តក់ក្នុងភ្នែក |
| ១០ | អុត | ជួសនៅស្បែកផ្ទាំងស្លាប |
| +៤៥ | អាសន្នរោគ ** | ក្នុងសាច់ដុំ |

*បរិមាណនៃការផ្តល់វ៉ាក់សាំង សូមមើលលំអិតនៅក្នុងបទដ្ឋានអនុវត្តបច្ចេកវិទ្យាស្តីពីការគ្រប់គ្រង និងការពារជំងឺញូកាស

**កន្លែងមកផលិតផលវ៉ាក់សាំងនេះ ត្រូវបានឈប់ប្រើប្រាស់ ហើយវាគ្មានលក់នៅតាមទីផ្សារទេ ទោះជាយ៉ាងនេះក្តី សូមធ្វើអនាម័យនិងសំអាតទីធ្លាទ្រុង រួមមាន ស្នូកទឹក និងចំណី អោយបានស្អាត និងផ្តល់ទឹកឱ្យមាន់ផឹក ទើបអាចការពារទប់ទល់នឹងជម្ងឺនេះបាន។

អរគុណដែលបានអានសៀវភៅនេះ

ហើយ

សូមសំណាងល្អចំពោះការចិញ្ចឹមមាន់របស់អ្នក!

មន្ទីរកសិកម្មខេត្តកណ្តាលរួមសហការជាមួយអង្គការវីវីអូប៊ីកម្ពុជា

With the support of
THE BELGIAN
DEVELOPMENT COOPERATION .be

vvob
education for development
Cambodia